# វត្តព្រះរតនារាម

## រដ្ឋ ម៉ាសាឈូសេត្ស Commonwealth of Massachusetts

# លក្ខន្តិកៈ

# Bylaws

[បកប្រែជាខេមរភាសាក្រៅផ្លូវការ នៅរដ្ឋម៉ាសាឈូសេត្ស សហរដ្ឋអាមេរិក។ ឯកសារដើមជាភាសាអង់គ្លេស។]

ខែធ្នូ គ.ស.២០០៦



Source: www.Templenews.info

# មាត្រា ១
## អំពីវត្តអារាម និងគោលការណ៍

ប្រការ ១: ឈ្មោះរបស់វត្តអារាម

ពុទ្ធិកៈសមាគម ឬសាជីវកម្មនេះ បានចុះឈ្មោះសមាគមជាមួយនាយកដ្ឋានរដ្ឋទទួលបន្ទុក អង្គការក្រៅរដ្ឋាភិបាលនិងសមាគម អាចដំណើរការបាន ក្រោមច្បាប់មានជាធរមានរបស់ រដ្ឋម៉ាសាឈូសេត្ស៍ មានឈ្មោះថា: វត្តត្រៃរតនារាម ។

ប្រការ ២: គោលការណ៍ និងបេសកកម្ម

ក-ស្ថាបនាមជ្ឈមណ្ឌលព្រះពុទ្ធសាសនាមួយ មានឈ្មោះថា: វត្តត្រៃរតនារាម ។

ខ-ធ្វើនិរន្តកម្មព្រះពុទ្ធសាសនាអោយបានគង់វង្សជាយូរអង្វែង ។

គ-រៀបចំការប្រជុំពុទ្ធសាសនិកជនខ្មែរនៅសហរដ្ឋអាមេរិក ដើម្បីបង្កើតមជ្ឈមណ្ឌលព្រះពុទ្ធ សាសនាជាតិមួយ ។

ឃ-បង្រៀន អប់រំ និងជួយណែនាំយុវវ័យខ្មែរជំនាន់ក្រោយអោយស្គាល់កេរ្តិ៍មតិករបស់គេ និងជំរុញអោយយុវវ័យទាំងនោះមានមោទនភាពលើកេរ្តិ៍តំណែលជាតិថែមទៀត ។

ង-ស្ថាបនាមជ្ឈមណ្ឌលព្រះពុទ្ធសាសនាជាតិមួយ ពុំមែនត្រឹមតែសំរាប់ជនរួមជាតិខ្មែរ ប៉ុណ្ណោះទេ គឺសំរាប់មនុស្សទាំងឡាយ ដែលមានឆន្ទៈចង់រៀនសូត្រ ចង់យល់ដឹង និងចង់ប្រណិបត្តិព្រះពុទ្ធសាសនា ។

ប្រការ ៣: អាស័យដ្ឋាន

មូលដ្ឋានរបស់សាជីវកម្ម ឬវត្តអារាម គឺស្ថិតនៅក្នុងទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត្ស៍ សហរដ្ឋអាមេរិក ។

ប្រការ ៤: ប្រថាប់ត្រារបស់វត្តអារាម

ពុទ្ធិកៈសមាគម ឬសាជីវកម្ម ត្រូវតែមានប្រថាប់ត្រាឬអត្តសញ្ញាប្រចាំវត្តអារាម ។



Source: www.Templenews.info

## មាត្រា ២

## សមាជិក សមាជិកា និងគណៈម្ចាស់ធិការវត្ត

ប្រការ ១: ប្រភេទនៃសមាជិកភាព

សមាជិកភាពរបស់ពុទ្ធិកៈសមាគមមានបីប្រភេទ :

ក-សមាជិកសាមញ្ញឬធម្មតា មនុស្សគ្រប់រូបមានសិទ្ធិទទួលសមាជិកភាពនៃប្រភេទនេះ ។

ខ-សមាជិកមួយជីវិត មនុស្សគ្រប់រូបមានសិទ្ធិទទួលសមាជិកភាពនៃប្រភេទនេះ ។

គ-សមាជិកកិត្តិយស បណ្ណានាយក និងកម្មិកៈសមាជិក [មានប្រធានវត្ត ១-រូប អនុប្រធាន ១-រូប លេខាធិការទទួលភារៈពតិមាន ១-រូប លេខាធិការទទួលភារៈធ្វើកំណត់ហេតុ ១-រូប និងហេរញ្ញិក ៣-រូប] មានសិទ្ធិបោះឆ្នោតជ្រើសតាំងបុគ្គលមួយរូបជាព្រះសង្ឃក្តី ជាគ្រហស្ថក្តីសំរាប់ឋានៈសមាជិកកិត្តិយស ដូច្នេះហើយបុគ្គលនោះ ត្រូវតែមានសុឆន្ទៈនិងជំហរខ្ពស់ក្នុងវិស័យឧបត្ថម្ភ និងគាំទ្រវត្តអារាម ។

ប្រការ ២: ការកម្រិតចំនួនសមាជិកភាពរបស់វត្តអារាម

ពុំត្រូវមានកំណត់ ឬមានការដាក់កម្រិតចំនួនសមាជិកភាពរបស់វត្តអារាមឡើយ ។

ប្រការ ៣: បុព្វសិទ្ធិរបស់សមាជិក

ក-សមាជិកភាពទាំងអស់របស់វត្តអារាម ត្រូវតែជាសិទ្ធិរបស់បុគ្គលតែម្នាក់គត់ ។ សមាជិកភាពនេះ ពុំអាចផ្ទេរអោយទៅបុគ្គលដទៃទៀតបានឡើយ ។

ខ-សមាជិកទាំងអស់ មានសិទ្ធិបោះឆ្នោត ឬមានសិទ្ធិទទួលតំណែងអ្វីមួយនៅក្នុងគណៈម្ចាធិការវត្ត ឬមានសិទ្ធិទទួលគុណប្រយោជន៍អំពីអចលនទ្រព្យសម្បត្តិឬទ្រព្យសម្បត្តិរបស់វត្តអារាម។

ប្រការ ៤: ទម្រង់បែបបទសមាជិកភាព

ក-ទម្រង់បែបបទសមាជិកភាព ត្រូវតែបំពេញនិងចុះហត្ថលេខាផ្ទាល់ដោយអ្នកដាក់ពាក្យស្នើចូលសមាជិកវត្តអារាម រួចហើយអាចកាន់យកទៅប្រគល់អោយវត្តនឹងដៃក៏បាន ឬផ្ញើតាមប្រព័ន្ធប្រៃសណីយ៍ក៏បាន។

ខ-មនុស្សគ្រប់រូប អាចដាក់ពាក្យស្នើចូលសមាជិករបស់វត្ត ទោះបីមានសញ្ជាតិជាអ្វីក៏ដោយ ។

ប្រការ ៥: ភាពបាត់បង់សមាជិកភាព

សមាជិកណា ដែលបានប្រព្រឹត្តកិរិយាមាយាទមិនល្អបណ្តាលអោយខូចប្រយោជន៍ប៉ះពាល់កិត្តិនាមនិងគុណប្រយោជន៍របស់វត្តអារាម ឬបានបំពារបំពានទៅលើលក្ខន្តិកៈវត្តអារាម ត្រូវតែបណ្តេញចេញពីវត្ត ឬសមាជិកភាពរបស់សមាជិកហ្នឹងត្រូវព្យួរទុកមួយរយៈ ឬអចិន្ត្រៃយ៍ យោងសម្លេងបោះឆ្នោតវិនិច្ឆ័យពីរភាគបី ២លើ៣នៃសមាជិកទាំងអស់របស់វត្តអារាម ។

ប្រការ ៦: កម្មិកៈសមាជិក ឬគណៈកម្មាធិការអចិន្ត្រៃយ៍

ក-ពុទ្ធិកៈសមាគម ឬវត្តអារាម ត្រូវមានសមាសភាព ដូចជាអាទិ៍: ប្រធានវត្ត ១-រូប អនុប្រធាន ១-រូប លេខាធិការទទួលភារៈពត៌មាន ១-រូប លេខាធិការទទួលភារៈធ្វើកំណត់ហេតុ ១-រូប និងហេរញ្ញិក ៣-រូប ។

ខ-ពុទ្ធិកៈសមាគម អាចមាននាយកដ្ឋានឬគណៈកម្មការបីបួនទៀត ដូចជាអាទិ៍: គណៈកម្មការផ្សព្វផ្សាយសាធារណៈ មានសមាជិក ៦-រូប គណៈកម្មការអក្សរសាស្ត្រនិងវប្បធម៌ មានសមាជិក ៣-រូប និងគណៈកម្មាធិការវត្ត មានសមាជិកបន្ថែម ៦-រូបទៀត ។

## មាត្រា ៣
## នីតិវិធីនៃការបោះឆ្នោត និងករណីយកិច្ចរបស់កម្មិកៈសមាជិក

ប្រការ ១: ការបោះឆ្នោតជ្រើសតាំងប្រធានវត្ត ត្រូវដំណើរការរៀងរាល់ឆ្នាំ

ក-គណៈកម្មាធិការវត្ត ត្រូវជ្រើសរើសសមាជិក ៣-រូប សំរាប់ជាបេក្ខជនប្រធានវត្ត អោយបានមួយខែមុនកិច្ចប្រជុំប្រចាំឆ្នាំ ដែលប្រព្រឹត្តទៅនៅក្នុងខែធ្នូ ។

ខ-សមាជិកគ្រប់រូបមានសិទ្ធិឈរជាបេក្ខជនប្រធានវត្ត ។ តំណែងប្រធាន អាចទទួលយកជាការបាន តម្រូវអោយមានសម្លេងគាំទ្រ ៥០ភាគរយ ៥០% នៃសមាជិករបស់វត្តអារាម ។

គ-តំណែងអនុប្រធាន លេខាធិការទទួលភារៈពត៌មាន លេខាធិការទទួលភារៈធ្វើកំណត់ហេតុ ហេរញ្ញិក ៣-រូប និងសមាជិកកម្មិកៈដទៃទៀត ត្រូវតែតែងតាំងដោយប្រធានឈ្នះឆ្នោត ពីរសប្តាហ៍ក្រោយវេលាកាលបោះឆ្នោតរួច ។

ប្រការ ២៖ ករណីយកិច្ចរបស់កម្មិកៈសមាជិក

ក-ប្រធានវត្ត ដឹកនាំកិច្ចប្រជុំទាំងអស់របស់វត្តអារាម និងកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការវត្ត ។ ប្រធានវត្ត ត្រូវដំណើរការដឹកនាំកិច្ចការទូទៅរបស់វត្តអារាម ។

ខ-អនុប្រធាន

នៅកាលៈទេសៈអវត្តមាន ឬមានភាពពិការឬអសមត្ថភាពរបស់ប្រធាន អនុប្រធានត្រូវប្រតិបត្តិករណីយកិច្ចទាំងអស់របស់ប្រធាន ។

គ-លេខាធិការទទួលភារៈពតិមាន ត្រូវសរសេរឬព្រាងបណ្តាលិខិត (សំបុត្រ) និងទម្រង់បែបបទផ្សេងៗទៀត សំរាប់កិច្ចប្រជុំទាំងអស់របស់វត្តអារាម ។ លេខាធិការទទួលភារៈពតិមានមានភារៈកិច្ចធ្វើការទាក់ទងតាមរយៈលិខិតស្នាមជាមួយសមាជិកនិងទីប្រឹក្សាទាំងអស់របស់វត្តអារាម ។

ឃ-លេខាធិការទទួលភារៈធ្វើកំណត់ហេតុ ត្រូវធ្វើកំណត់ហេតុកិច្ចប្រជុំទាំងអស់របស់វត្តអារាម និងត្រូវធ្វើកំណត់ហេតុកិច្ចប្រជុំទាំងអស់របស់គណៈកម្មាធិការវត្ត  រក្សាទុកបញ្ជីសមាជិកអោយបានត្រឹមត្រូវ ទៀងទាត់និងទាន់ពេលវេលា ហើយបន្ថែមពីហ្នឹង លេខាធិការទទួលភារៈធ្វើកំណត់ហេតុ ត្រូវប្រតិបត្តិការងារមួយចំនួនទៀត ដែលគណៈកម្មាធិការវត្តប្រគល់អោយ ។ លេខាធិការទទួលភារៈធ្វើកំណត់ហេតុ ត្រូវផ្ញើសេចក្តីជំរាបនិងអញ្ជើញកិច្ចប្រជុំទាំងអស់របស់វត្តអារាមទៅសមាជិក យោងការកំណត់របស់លក្ខន្តិកៈ ។

ង-ហេរញ្ញិក

ហេរញ្ញិកទាំងបី ៣-រូប ត្រូវតែប្រមូលនិងទូទាត់សងបច្ច័យនិងបំណុល តាមការកំណត់របស់ប្រធាន និងគណៈកម្មាធិការវត្ត ។ ក្រុមហេរញ្ញិកទាំងបី ៣-រូប ត្រូវតែរក្សាទុកអោយបានត្រឹមត្រូវ ទៀងទាត់ ទាន់ពេលវេលា និងមានតម្លាភាព នូវគណនេយ្យឬបញ្ជីបច្ច័យ និងប្រាក់ចំណូលនិងចំណាយសំរាប់វត្តអារាម ។

ច-គណៈកម្មការផ្សព្វផ្សាយសាធារណៈ មានភារៈផ្សព្វផ្សាយការងាររបស់វត្តអារាមនិងរៀបចំធ្វើព្រឹត្តិប័ត្រប្រចាំខែធ្វើប្រគេននិងជូនព្រះសង្ឃ ពុទ្ធបរិស័ទ និងសមាជិកបានជ្រាបអំពីដំណើរការការងាររបស់វត្តអារាម ។

ឆ-គណៈកម្មការអក្សរសាស្ត្រនិងវប្បធម៌ មានភារៈកិច្ចបង្រៀន អប់រំ និងណែនាំយុវវ័យខ្មែរអំពីអក្សរសាស្ត្រ និងវប្បធម៌ជាតិ ។

ជ-គណៈកម្មាធិការវត្ត មានសមាសភាពដូចជាអាទិ៍ៈ កម្មិកៈសមាជិក សមាជិកនៃបណ្តាគណៈកម្មាធិការវត្តអារាម រួមទាំងប្រធានសមាគមខ្មែរនៃទីក្រុងឡូវែលមួយរូបដែរ ។

## មាត្រា ៤

## គុណប្រយោជន៍សំរាប់សមាជិករបស់វត្ត

ប្រការ ១ៈ ក-គ្រួសារ ដែលមានសមាជិកភាពជាមួយវត្តអារាម ត្រូវតែទទួលបាននូវការបង្រៀននិងអប់រំកុលបុត្រនិងកុលធីតារបស់ពួកលោក ដោយពុំគិតកម្រៃឡើយ ។

ខ-សមាជិកទាំងអស់របស់វត្តអារាម ត្រូវតែទទួលបាននូវព្រឹត្តិប័ត្រ ឬពតិមានរបស់វត្តអារាមដោយពុំគិតកម្រៃឡើយ ។

## មាត្រា ៥

## កិច្ចប្រជុំនិងសន្និបាតរបស់វត្ត

ប្រការ ១ៈ កិច្ចប្រជុំសាមញ្ញ ធម្មតាឬប្រចាំខែ និងកិច្ចប្រជុំប្រចាំឆ្នាំ

កិច្ចប្រជុំត្រូវតែមានប្រជុំជារៀងរាល់ខែ និងកិច្ចប្រជុំប្រចាំឆ្នាំ ត្រូវតែប្រព្រឹត្តឡើងនៅក្នុងខែធ្នូជារៀងរាល់ឆ្នាំ ។ បណ្តាកិច្ចប្រជុំនានា ត្រូវតែប្រព្រឹត្តឡើង ជាបណ្តោះអាសន្ន នៅតាមគេហដ្ឋានកំណត់របស់វត្ត នៅទីក្រុងឡូវែល ។

ប្រការ ២: កិច្ចប្រជុំវិសាមញ្ញ

កិច្ចប្រជុំវិសាមញ្ញឬពិសេសរបស់វត្តអារាម អាចកោះហៅប្រជុំបានដោយប្រធាន ឬសមាជិកពិរភាគបី ២លើ៣នៃគណៈកម្មាធិការវត្ត ។

## មាត្រា ៦

## អំពីហិរញ្ញវត្ថុរបស់វត្ត

ប្រការ ១: បណ្ដាហេរញ្ញិកទាំងបី ៣-រូប ហេរញ្ញិកពីរ ២-រូប មានសិទ្ធិ ឬត្រូវតែ ចុះហត្ថលេខារួមគ្នា នៅលើសែកនិងប័ណ្ណប្រាក់ មុននឹងប្រើប្រាស់ ដោយមានការអនុម័តពីប្រធាន ។

ប្រការ ២: បច្ច័យ វិភាគទាន និងប្រាក់ចំណូលទាំងអស់ពេលទទួលបាន ត្រូវតែដាក់បញ្ចូលទៅក្នុងគណនេយ្យធនាគាររបស់វត្តអារាមភ្លាម ។

ប្រការ ៣: ប្រធាន និងហេរញ្ញិក អាចប្រើប្រាស់ប្រាក់របស់វត្តអារាមបាននៅគ្រប់ថេរៈវេលា ល្គឹកណាប្រាក់ចំណាយទាំងនោះពុំលើសចំនួនមួយរយហាសិប ១៥០ដុល្លារ ប្រសិនបើមិនដូច្នេះទេ ប្រាក់ចំណាយត្រូវតែដាក់ស្នើទៅនិងអនុម័តដោយគណៈកម្មាធិការវត្ត លើកលែងតែប្រាក់ចំណាយសំរាប់បង់ថ្លៃអាគារប្រចាំខែ ។

ប្រការ ៤: ប្រាក់ចំណាយចំនួនមួយរយ ១០០ដុល្លារ មានសំរាប់ជាសោហ៊ុយរបស់ប្រធាន ហើយប្រធាននឹងផ្ដល់វិក្កយប័ត្រឬប្រកាន់ដៃនៃការចាយនោះទៅហេរញ្ញិកវិញ ។

## មាត្រា ៧

## នីតិវិធីនៃការធ្វើវិសោធនកម្មលក្ខន្តិកៈ

លក្ខន្តិកៈនេះអាចធ្វើវិសោធនកម្ម ឬស្នើកែប្រែបាន នៅរវៀងរាល់សន្និបាទប្រចាំឆ្នាំ ឬនៅរវៀងរាល់កិច្ចប្រជុំវិសាមញ្ញ ប្រយោជន៍ផ្ដោតទៅលើរបៀបវារៈស្នើធ្វើវិសោធនកម្មលក្ខន្តិកៈនេះតែមួយគត់ ដោយមានសម្លេងសមាជិកវត្តមានពីរភាគបី ២លើ៣ បោះឆ្នោតគាំទ្រ ហើយត្រូវតែមានការផ្ដល់ដំណឹងអោយបានសាមសិប ៣០ថ្ងៃមុនពីលេខាធិការ ផ្ញើប្រគេននិងជូនពតិមានទៅសមាជិកទាំងអស់ តាមរយៈប្រព័ន្ធប្រៃសណីយ៍ មានភ្ជាប់ជាមួយនូវសេចក្ដីព្រាងស្ដីពីសំណើធ្វើវិសោធនកម្មលក្ខន្តិកៈផង៕

*[ បកប្រែជាខេមរភាសាក្រៅផ្លូវការ នៅរដ្ឋម៉ាសាឈូសេត្ស៍ សហរដ្ឋអាមេរិក ។ ឯកសារដើមជាភាសាអង់គ្លេស ។]*